01575081

**Declassified to Public**
**19 December 2018**

E378/8/6

ORIGINAL DOCUMENT/DOCUMENT ORIGINAL
(Date of receipt/Date de réception): 26 / 06 / 2018
(Time/Heure): 15:00
(Case File Officer/L'agent chargé du dossier): SANN RADA

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

ប្រធានគណៈមេធាវី
មេធាវី សួន វិសាល
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី សាំង ទណ្ឌៈ
២-មេធាវី អ៊ុំ កិរិយា
៣-មេធាវី កែត ឃី
៤-មេធាវី អ៊ឹម ប៉ូលី
៥-មេធាវី ខៀវ សំបូរ
៦-មេធាវី ជា សុភក្ខន
៧-មេធាវី សាន់ ជួយ
៨-មេធាវី ហាន ផានិត
៩-មេធាវី ជុ ចាន់ធីរ៉ា
១០-មេធាវី កេន សុម៉ាណ្ឌា
១១-មេធាវី ម៉ី ឧសភា
១២-មេធាវី សេង សុខឃីម
១៣-មេធាវី លីម សុវណ្ណា
១៤-មេធាវី ឈឹម តិរទ្ធ
១៥-មេធាវី សំ សុគង់
១៦-មេធាវី នង មានល្អ
១៧-មេធាវី អ៊ី ធីតាពៅ
១៨-មេធាវី លី ពិច
១៩-មេធាវី ឈឹម វិសុត្ត
២០-មេធាវី លឹម ច័ន្ទលីដា
២១-មេធាវី កែ វិសាល
២២-មេធាវី ហូ លីហួច
២៣ មេធាវី អ៊ា ពិសី
២៤ មេធាវី ជា ហុងរី
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី អ៊ុំ វិមានចំប៉ា
២៧-មេធាវី ឈី សម្បត្តិ

លេខ ១៦១២ /គម/១៨

ថ្ងៃ ព្រហស្បតិ៍ ៩កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១៨

**ជម្រាបជូន**

**លោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**នៃអ.វ.ត.ក**

**កម្មវត្ថុ** ÷ អំពីឋានៈរបស់សហមេធាវីអន្តរជាតិការពារក្តីអោយ **នួន ជា** ក្នុងសំណុំរឿង ០០២/០២ ។

**យោង** ÷ - លិខិតចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៨ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជា ។

- កិច្ចប្រជុំក្រុមប្រឹក្សាគណៈមេធាវីថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១៨
- មាត្រា ៤៨ នៃច្បាប់ លក្ខន្តិកៈគណៈមេធាវី

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោកប្រធានមេត្តាជ្រាបថា : ក្រោយពីខ្ញុំបានទទួលលិខិតរបស់លោកមក គណៈមេធាវីបានបើកកិច្ចប្រជុំក្រុមប្រឹក្សាគណៈមេធាវី នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ ដើម្បីពិភាក្សា និងដោះស្រាយចំពោះសំណើរបស់លោក។ ផ្អែកលើលទ្ធផលនៃកិច្ចប្រជុំនេះ ខ្ញុំសូមឆ្លើយនឹងសំណួររបស់លោកដូចតទៅនេះ៖

**សំណួរ** ក ៖ បន្ទាប់ពីចុះបញ្ជីជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាហើយ តើមេធាវីបរទេសដែលប្រកបវិជ្ជាជីវៈនៅចំពោះមុខ អ.វ.ត.ក ចាំបាច់ត្រូវស្ថិតនៅជាសមាជិកគណៈមេធាវីបរទេសជាបន្តទៅទៀត ឬយ៉ាងណា?

**ចម្លើយ** ៖ ការប្រកបវិជ្ជាជីវៈនៃមេធាវីបរទេសនៅចំពោះមុខយុត្តាធិការកម្ពុជាអាស្រ័យលើកត្តាពិចារណាពីរ ដូចដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។

**<u>កត្តាពិចារណាទីមួយ</u>** ៖ មេធាវីបរទេសនោះត្រូវបានប្រទេសដើមទទួលស្គាល់ឱ្យប្រកបវិជ្ជាជីវៈមេធាវី ទើបមានសិទ្ធិចូលរួមប្រកបវិជ្ជាជីវៈជាមួយមេធាវីខ្មែរក្នុងយុត្តាធិការខ្មែរបាន។ នេះជាកត្តាពិចារណាដែលអាចឱ្យមេធាវីបរទេសអាចចុះបញ្ជីជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបាន ។/

**<u>កត្តាពិចារណាទីពីរ</u>** ៖ ពាក្យថា "ប្រទេសដើមរបស់ខ្លួនទទួលស្គាល់ឱ្យប្រកបវិជ្ជាជីវៈមេធាវី" បើគិតទៅតាមពេលវេលា ត្រូវទៅទន្ទឹមគ្នា (synchronized) ជាមួយនឹងពេលប្រកបវិជ្ជាជីវៈនៅប្រទេសកម្ពុជាដែរ។ មានន័យថា បើការទទួលស្គាល់នោះត្រូវបញ្ចប់ដោយប្រការណាមួយ ការប្រកបវិជ្ជាជីវៈនៅប្រទេសកម្ពុជាត្រូវបញ្ចប់ជាមួយគ្នាដែរ ព្រោះការចុះបញ្ជីនៅក្នុងបញ្ជីសមាជិកគណៈមេធាវីនៃប្រទេសកម្ពុជា ក៏ដោយសារតែគណៈមេធាវីទទួលស្គាល់បុគ្គលដែលសុំចុះបញ្ជីនោះមានឋានៈជាមេធាវីដែរ។ កាលណា បុគ្គលនោះបាត់បង់ឋានៈជាមេធាវី នៃប្រទេសដើមរបស់ខ្លួន គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មិនអាចទទួលស្គាល់បុគ្គលនោះក្នុងឋានៈមេធាវីបានឡើយ ហើយជននោះក៏មិនអាចប្រកបវិជ្ជាជីវៈមេធាវីក្នុងដែនយុត្តាធិការកម្ពុជាបានដែរ។

**សំណួរ ខ** ៖ ប្រសិនបើមេធាវីបរទេសដែលប្រកបវិជ្ជាជីវៈនៅចំពោះមុខ អ.វ.ត.ក លែងជាសមាជិកគណៈមេធាវីបរទេសណាមួយ តើចំណុចនេះមានផលប៉ះពាល់អ្វីដែរឬទេ ដល់ការចុះឈ្មោះរបស់មេធាវីបរទេសនោះនៅក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា?

**ចម្លើយ**៖ កាលណាមេធាវីណាម្នាក់ ទោះជាខ្មែរក្តី បរទេសក្តី បានចុះបញ្ជីក្នុងបញ្ជីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាហើយ មេធាវីនោះត្រូវស្ថិតនៅក្រោមវិធាននៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីដូចគ្នា។ កាលណាមេធាវីណាម្នាក់បាត់បង់លក្ខណៈសម្បត្តិជាមេធាវី មេធាវីនោះត្រូវដាក់ឱ្យស្ថិតនៅក្រៅបញ្ជី។ មាត្រា ៤១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីចែងថា ៖ "ក្រុមប្រឹក្សាគណៈមេធាវីអាចសម្រេចដាក់មេធាវីណាម្នាក់នៅក្រៅបញ្ជីបើមេធាវីនោះស្ថិតក្នុងស្ថានភាពវិសមិតភាព ឬមេធាវីនោះពុំអាចប្រកបវិជ្ជាជីវៈរបស់ខ្លួនបាន។ ក្នុងករណីមានបណ្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចខាងលើនោះ ត្រូវអនុវត្តនីតិវិធី ដែលមានចែងក្នុងមាត្រា ៣៣។"

ក្នុងន័យនេះ បើមេធាវីបរទេសណាម្នាក់លែងជាសមាជិកគណៈមេធាវីបរទេសណាមួយ ជាគោលការណ៍សាកល មេធាវីនោះក៏មិនមានលក្ខណៈអាចប្រកបវិជ្ជាជីវៈមេធាវីក្នុងប្រទេសនោះដែរ។ ក្រុមប្រឹក្សាគណៈមេធាវីមានភារកិច្ចត្រូវដកឈ្មោះមេធាវីនោះចេញពីបញ្ជី គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**សំណួរ គ** ៖ លោក Victor Koppe ពុំមែនជាសមាជិកគណៈមេធាវីបរទេសណាមួយចាប់តាំងពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៦ មក តើការចុះឈ្មោះរបស់គាត់នៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានៅមានសុពលភាពដែរឬទេ?

**ចម្លើយ** ៖ យោងតាមមាត្រា ៤១ ដដែល ការដាក់ឱ្យនៅក្រៅបញ្ជីត្រូវតែធ្វើតាមនីតិវិធីច្បាប់។ សេចក្តីសម្រេចដាក់នៅក្រៅបញ្ជីនេះត្រូវធ្វើដោយការប្រជុំនៃក្រុមប្រឹក្សាគណៈមេធាវី។ ការប្រជុំក្រុមប្រឹក្សាគណៈមេធាវីត្រូវអនុលោមតាមបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី។

**សំណួរ ឃ** ៖ ប្រសិនបើការចុះឈ្មោះរបស់គាត់នៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា លែងមានសុពលភាព តើគាត់ចាំបាច់ត្រូវធ្វើអ្វីខ្លះ ដើម្បីកែតម្រូវស្ថានភាពនេះ?/

**ចម្លើយ៖** យោងតាមមាត្រា ៤២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី "មេធាវីដែលត្រូវបានដាក់ឱ្យនៅក្រៅបញ្ជី ពុំអាចប្រកបវិជ្ជាជីវៈរបស់ខ្លួន ហើយក៏ពុំអាចប្រើប្រាស់ឋានៈជាមេធាវីបានឡើយ និងត្រូវបានរួចពីកាតព្វកិច្ច ទាំងឡាយដែលទាក់ទងទៅនឹងវិជ្ជាជីវៈនេះ ក៏ប៉ុន្តែត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈមេធាវី" ។ ឃ្លា ចុងក្រោយដែលថា "ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈមេធាវី" នេះមានន័យថា សាមីមេធាវីអាចបញ្ចូល មកក្នុងបញ្ជីគណៈមេធាវីវិញបាន ប្រសិនបើការដាក់នៅក្រៅបញ្ជីនេះមានរយៈពេលកំណត់។ ក្នុងករណី ដែល លោក Koppe ចង់ប្រកបវិជ្ជាជីវៈនៅក្នុងយុត្តាធិការកម្ពុជាឡើងវិញ គាត់អាចស្តារសម្បទារបស់គាត់នៅក្នុង ប្រទេសដើមរបស់គាត់ ហើយដាក់ពាក្យសុំគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បញ្ចូលក្នុងបញ្ជីឡើងវិញ ក្រោមការសម្រេចរបស់ក្រុមប្រឹក្សានៃគណៈមេធាវី ។

ទាក់ទងនឹងករណីរបស់លោក Victor Koppe ខ្ញុំសូមស្នើសុំលោកប្រធានមេត្តា ផ្តល់ព័ត៌មាន និងឯកសារ ជាក់លាក់ ទាក់ទងនឹងឋានៈរបស់គាត់ជាមួយគណៈមេធាវីបរទេស មកគណៈមេធាវី ជាផ្លូវការ អោយបានមុន ថ្ងៃព្រហស្បតិ៍ ទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដើម្បីអោយគណៈមេធាវីសម្រេចលើឋានៈមេធាវីរបស់គាត់ ។

ស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានជ្រាបជាព័ត៌មាន ។/

ប្រធាន